ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១០ លេខ ៧

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

កសវ



Work Activities

ប្រចាំខែកក្កដា ឆ្នាំ២០១៧



# មាតិកា


| ល.រ | បរិយាយ | លេខទំព័រ |
|---|---|---|
| I- | កិច្ចប្រជុំជំនាញបច្ចេកទេស | |
| | ១- សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | ១-២ |
| | ២- សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីស្តង់ដារកម្ពុជា | ៣-៤ |
| II- | សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត (ក្រុម RIA) | |
| | ១- វគ្គបណ្តុះបណ្តាលអំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត | ៥-៧ |
| | ២- សិក្ខាសាលាផ្សព្វផ្សាយស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត | ៨-៩ |
| III- | កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆមាសទី១ ឆ្នាំ២០១៧ | ១០-១៧ |
| IV- | សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៧ | ១៨-១៩ |

# ១- សេចក្តីព្រាងច្បាប់ស្តីពី
## ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

កាលពីថ្ងៃទី៤ និងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព លោកជំទាវ **តាល់ ណៃអ៊ីម** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងពាណិជ្ជកម្ម។



តាមរយៈកិច្ចព្រមព្រៀងស្តីពី E-ASEAN ជាមួយនឹងការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះអង្គការពាណិជ្ជកម្មពិភពលោក (WTO) រួមជាមួយបណ្តាសមាជិកអាស៊ាន រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចនូវការប្តេជ្ញាចិត្តក្រោមក្របខណ្ឌ E-ASEAN តាមរយៈការរៀបចំ និងការអនុម័តច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce)។ ក្រសួងពាណិជ្ជកម្មទទួលបន្ទុកដឹកនាំរៀបចំសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានតាក់តែងឡើង ដើម្បីផ្តល់សារៈប្រយោជន៍ដូចខាងក្រោម៖

-សម្រួលដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទាំងក្នុងប្រទេសនិងទាំងអន្តរជាតិ ដោយលុបបំបាត់របាំងនានា និងបង្កើតភាពប្រាកដប្រជាផ្លូវច្បាប់ ព្រមទាំងបង្កើនទំនុកចិត្តក្នុងចំណោមអាជីវករពាណិជ្ជករ និងអ្នកប្រើប្រាស់ក្នុងប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិត្រូនិក

-លើកទឹកចិត្តដល់ការប្រើប្រាស់ទម្រង់ដែលអាចជឿទុកចិត្តបាននៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិ-ត្រូនិក ដែលអាចជួយបង្កើតទំនាក់ទំនងពាណិជ្ជកម្មទាំងក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា

-សម្រួលដល់ការរក្សាឯកសារទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិត្រូនិកជាមួយពាណិជ្ជករ និងពាណិជ្ជករ និងរវាងពាណិជ្ជករជាមួយនឹងស្ថាប័នសាធារណៈ ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងជំរុញការផ្តល់សេវាតាមប្រព័ន្ធអេឡិត្រូនិកប្រកបដោយប្រសិទ្ធភាពតាមមធ្យោបាយដែលអាចជឿទុកចិត្តបាន

-លើកស្ទួយទំនុកចិត្តពីសាធារណជនចំពោះយថាភូតភាព សុក្រិតភាព និងភាពអាចជឿទុកចិត្តបាននៃទំនាក់ទំនងតាមប្រព័ន្ធអេឡិត្រូនិក

-រារាំងការប្រព្រឹត្តអំពើដែលបង្កការខូចខាតដល់ទិន្នន័យ និងប្រព័ន្ធព័ត៌មាន។

លក្ខណៈពិសេសរួមរបស់ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិត្រូនិក គឺទទួលស្គាល់ទំនាក់ទំនងរបស់ភាគីពាណិជ្ជកម្ម ដោយមិនចាំបាច់ប្រើប្រាស់លិខិតស្នាមជាក្រដាសដែលជាទម្លាប់ប្រើតាមកិច្ចសន្យាទូទៅ និងការប្រើប្រាស់កន្លងមក។

ម្យ៉ាងទៀត ច្បាប់នេះជាវិធានមួយសម្រាប់បង្កើតកិច្ចសន្យានិងធានាសុពលភាព នៃកិច្ចសន្យាទាំងឡាយ ដែលភាគីបានចុះកិច្ចព្រមព្រៀងតាមប្រព័ន្ធអេឡិត្រូនិក ព្រមទាំងរក្សាទិនន្ន័យសារអេឡិត្រូនិក ក្នុងគោលបំណងទទួលស្គាល់អ្នកទទួលសារអេឡិចត្រូនិក និងកំណត់ពេលវេលា និងទីកន្លែងរបស់អ្នកផ្ញើ និងអ្នកទទួលសារអេឡិចត្រូនិក[១]។



អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕

---

(១) អត្ថបទនេះដកស្រង់ពីកំណត់មូលហេតុសង្ខេបនៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

# ២- សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពី

## ស្តង់ដារកម្ពុជា

កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព លោកជំទាវ **នាល់ ណៃអ៊ីម** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ម៉ា ពិសី** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីស្តង់ដារកម្ពុជា** ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម។



ការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) របស់ព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ២០០៤ គឺជាកត្តាប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាក្នុងនាមជាប្រទេសអភិវឌ្ឍន៍យឺត បានឈានឡើងនៅក្នុងជួរនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ ប្រទេសកម្ពុជាបានខិតខំជាច្រើនឆ្នាំ ដើម្បីបុព្វហេតុដ៏មានសារៈសំខាន់ចំពោះសេដ្ឋកិច្ចជាតិ។

បន្ទាប់ពីបានចូលជាសមាជិកនៃអង្គការ WTO កម្ពុជាបានសម្រេចបង្កើតច្បាប់ស្តីពីស្តង់ដារកម្ពុជា ដើម្បីបំពេញតាមការតម្រូវរបស់អង្គការនេះ និងធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាព សេវាកម្ម និងការគ្រប់គ្រង ធានាឲ្យការធ្វើពាណិជ្ជកម្មមានលក្ខណៈត្រឹមត្រូវ និងងាយស្រួល បង្កើនការការពារអ្នកប្រើប្រាស់ និងលើកកម្ពស់សុខមាលភាពសាធារណៈ។

បន្ទាប់មកនៅក្នុងអង្គប្រជុំកាលពីឆ្នាំ២០១២ នៅទីក្រុងហ្សឺណែវ នៃប្រទេសស្វីស អង្គការ WTO បានតម្រូវឲ្យកម្ពុជាធ្វើវិសោធនកម្មលើច្បាប់ស្តីពីស្តង់ដារកម្ពុជា ៤ ចំណុច ដូចខាងក្រោម៖

១.កែសម្រួលនិយមន័យ "ស្តង់ដារ" ឲ្យស្របតាមនិយមន័យនៃកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម របស់អង្គការ WTO (World Trade Organization Technical Barriers to Trade-WTO – TBT)

២.ប្រើពាក្យ "បទប្បញ្ញត្តិបច្ចេកទេស" ជំនួសឲ្យពាក្យ "ស្តង់ដារបញ្ជា" ដើម្បីឲ្យសមស្របតាមកិច្ចព្រមព្រៀង WTO-TBT

៣.ដកជំពូកស្តីពី "ការវាយតម្លៃទទួលស្គាល់ និងការចុះបញ្ជី" ចេញពីច្បាប់ស្តីពីស្តង់ដារកម្ពុជា ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍នៅក្នុងការអនុវត្តការវាយតម្លៃភាពអនុលោម

៤.បង្កើតឲ្យមាននីតិវិធីនៃការកំណត់ "បទប្បញ្ញត្តិបច្ចេកទេស" ស្របតាមកិច្ចព្រមព្រៀង WTO-TBT។

ម៉្យាងវិញទៀត នៅក្នុងការអនុវត្តជាក់ស្តែង ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានជួបប្រទេះនូវផលលំបាកមួយចំនួន ដោយមន្ត្រីអធិការកិច្ចរបស់វិទ្យាស្ថានស្តង់ដារកម្ពុជាពុំមាននីតិសម្បទាឲ្យពិនិត្យបទល្មើសដែលមានចែងនៅក្នុងច្បាប់ស្តីពីស្តង់ដារកម្ពុជា ស្របតាមបទប្បញ្ញត្តិនៃក្របនីតិវិធីព្រហ្មទណ្ឌ និងការប្រើឈ្មោះវិទ្យាស្ថាន ជាហេតុធ្វើឲ្យសាធារណៈជនមានយល់ច្រលំថា វិទ្យាស្ថានស្តង់ដារកម្ពុជា ជាគ្រឹះស្ថានសិក្សាឯកជន មិនមែនជាស្ថាប័នរបស់រាជរដ្ឋាភិបាលឡើយ។ ម៉្យាងទៀតនៅក្នុងបណ្តាប្រទេសសមាជិកសហគមន៍សេដ្ឋកិច្ចអាស៊ាន អង្គការស្តង់ដារជាតិនៃប្រទេសនីមួយៗ គឺជាស្ថាប័នរដ្ឋ ដោយបានបង្កើតជាអគ្គនាយកដ្ឋានស្តង់ដារ ហេតុនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្នើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីស្តង់ដារកម្ពុជាទៅលើ២ចំណុចបន្ថែមទៀត ដូចខាងក្រោម៖

១.ផ្តល់នីតិសម្បទាដល់មន្ត្រីអធិការរបស់វិទ្យាស្ថាន និងមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្តទទួលនីតិសម្បទាឲ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃនីតិព្រហ្មទណ្ឌ។

២.ប្តូរឈ្មោះ "វិទ្យាស្ថានស្តង់ដារកម្ពុជា" ទៅជា "អគ្គនាយកដ្ឋានស្តង់ដារកម្ពុជា" និង "ប្រធានវិទ្យាស្ថាន" ទៅជា "អគ្គនាយក"[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងវិសោធនកម្មនេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីស្តង់ដារកម្ពុជា។

# ១- វគ្គបណ្តុះបណ្តាលអំពីវិធីសាស្រ្តវាយតម្លៃ លើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

## (Regulatory Impact Assessment Implementation)

## នៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ





នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី បានបើកវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្រ្តវាយ តម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (Regulatory Impact Assessment Methodology) ជូនដល់ មន្ត្រីនិងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចំនួនប្រមាណ ៥០រូប ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ នៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ។

ឯកឧត្តម **ម៉ិច សុខា** អគ្គលេខាធិការរង ECOSOCC និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត និងឯកឧត្តម **អេង រត្នមុនី** អគ្គលេខាធិការរង ECOSOCC និងជាប្រធានផ្នែកបណ្តុះបណ្តាល នៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត វាគ្មិនក្នុងវគ្គបណ្តុះបណ្តាលនេះ។



ជាកិច្ចចាប់ផ្ដើមវគ្គបណ្ដុះបណ្ដាល ឯកឧត្ដម អគ្គលេខាធិការ ក្រុមប្រឹក្សាធម្មនុញ្ញ បានមតិស្វាគមន៍ថា " ជាបឋម ក្នុងនាមមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ និងក្នុងនាមខ្ញុំ ផ្ទាល់ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្ដមទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ប្រធានក្រុមប្រឹក្សា សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្ដីការគណៈរដ្ឋមន្ត្រី ដែលបានឯកភាពតាមសំណើសុំរបស់យើងខ្ញុំ និងបានចាត់ឯកឧត្ដមទាំងពីរ អញ្ជើញមកធ្វើបទឧទ្ទេសនាមអំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ចំនួន ២ថ្ងៃ គឺនៅថ្ងៃទី១៧ និងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ នេះ នៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ព្រមទាំងបានផ្ដល់អាហារសម្រន់និងអាហារថ្ងៃត្រង់ថែមទៀត។ លើសពីនេះទៅទៀត សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះឯកឧត្ដមទេសរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សា សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្ដីការគណៈរដ្ឋមន្ត្រី ដែលបានផ្ដល់កុំព្យូទ័រយួរដៃចំនួន ០៤គ្រឿង ព្រីនធ័រចំនួន ០១គ្រឿង និងឧបករណ៍ថតសំឡេងចំនួន ០១គ្រឿង ដល់ក្រុមការងារវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញដើម្បីបំពេញការងារ។

តទៅនេះ ខ្ញុំសូមជម្រាបជូនឯកឧត្ដមជាគ្រូឧទ្ទេស អំពីសមាសភាពចូលរួមស្ដាប់បទឧទ្ទេសនាមនាពេលនេះមាន ឯកឧត្ដមអគ្គលេខាធិការរង នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្ដម លោក លោកស្រី នាងកញ្ញា ជាមន្ត្រីខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គនាយក អគ្គនាយករង ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យសរុបទាំងអស់ចំនួនប្រមាណ ៥០ នាក់។

ខ្ញុំសង្ឃឹមថា វគ្គបណ្តុះបណ្តាលនេះ អាចចាត់ទុកជាការទទួលចំណេះដឹង និងបទពិសោធន៍ថ្មីដែលនាំឲ្យមានការយល់ដឹងមួយកម្រិតថែមទៀត។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោក លោកស្រី នាងកញ្ញា សូមជួបប្រកបតែនឹង ពុទ្ធពរទាំង៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

តទៅនេះ ខ្ញុំសូមប្រកាសបើកវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងសង្ឃឹមថា ឯកឧត្តម លោក លោកស្រី នាងកញ្ញា នឹងខិតខំក្រេបយកចំណេះដឹង និងបទពិសោធន៍របស់ឯកឧត្តមគ្រូឧទ្ទេស ដើម្បីបំពេញការងារជូនស្ថាប័ន ជូនជាតិមាតុភូមិឲ្យបានរីកចម្រើន។ ”៕



# ២- សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី ការវាយតម្លៃ លើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត




កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ដោយមានការជួយគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ុ ADB បានរៀបចំសិក្ខាសាលាស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA)នៅក្រសួងបរិស្ថាន ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានក្រុមប្រតិបត្តិកតិយុត្ត និងឯកឧត្តម **អ៊ាង សុផល្លែត** អនុរដ្ឋលេខាធិការ និងជាតំណាងឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

ធនាគារអភិវឌ្ឍន៍អាស៊ី ADB រួមជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី បានបង្កើតគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ហៅ កាត់ថា RIA។ ការបង្កើតគម្រោង RIA ក្នុងបំណងពង្រឹងការធ្វើកំណែទម្រង់បញ្ញត្តិកម្ម សម្រេចបានឲ្យនូវវប្បធម៌បង្កើតគោលនយោបាយ និងអភិបាលកិច្ចកាន់តែប្រសើរ តាមរយៈការដាក់ឲ្យអនុវត្តប្រព័ន្ធវាយតម្លៃលើលិខិតបទដ្ឋានគតិយុត្ត ពេលជំរុញឲ្យមានការវាយតម្លៃ និងសិក្សាឲ្យបានល្អិតល្អន់បំផុតមុនចេញលិខិតបទដ្ឋានគតិយុត្ត និងបញ្ញត្តិកម្ម ធ្វើយ៉ាងណាកាត់បន្ថយផលប៉ះពាល់ជាអតិបរមានៅក្នុងសង្គម។



ទាំង ឯកឧត្តម **យឹម ណុលសន** និងឯកឧត្តម **អ៊ាង សុផល្លែត** បានថ្លែងថា ការធ្វើបញ្ញត្តិកម្មមានសារសំខាន់ណាស់ និងចាំបាច់សម្រាប់សង្គមនីមួយៗ ដើម្បីគ្រប់គ្រងសង្គមឲ្យចម្រើន និងប្រសើរឡើង តែវាក៏នាំមកនូវផលប៉ះពាល់ផងដែរ ជៀសមិនផុតឡើយ តែរាជរដ្ឋាភិបាលក៏ត្រូវតែប្រុងប្រយ័ត្នធ្វើកុំឲ្យបញ្ញត្តិកម្មទាំងនោះមានផលអវិជ្ជមានមិនចាំបាច់ដល់អ្នកប្រតិបត្តិតាម។ «RIA ទាមទារឲ្យក្រសួងត្រូវអនុវត្តគោលការណ៍ប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អក្នុងការរៀបចំសំណើលិខិតបទដ្ឋានគតិយុត្ត និងវាយតម្លៃឲ្យបានល្អិតល្អន់លើបញ្ញាត្តិកម្មណាមានផលប៉ះពាល់ដល់ធុរកិច្ច»។

ក្នុងឱកាសនោះ ឯកឧត្តម **ម៉ិច សុខា** បានបង្ហាញពីទិដ្ឋភាពរួមនៃវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដល់សិក្ខាកាមទាំងអស់ ឲ្យបានយល់ដឹងអំពីសារៈប្រយោជន៍ពីការប្រើប្រាស់វិធីសាស្ត្រនេះ៕



# III- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆមាសទី១ ឆ្នាំ២០១៧



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា **ប្រចាំឆមាសទី១ ឆ្នាំ២០១៧**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០១៧ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលសុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡បើប្រៀបធៀបក្នុងឆមាសទី១ដូចគ្នាឆ្នាំ២០១៧និងឆ្នាំ២០១៦ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើង៣,៥% ដែលអាចចាត់ទុកថា ជាកម្រិតមធ្យមបើធៀបនឹងការចែងក្នុងគោលនយោបាយ (៣% - ៥%)។

តារាង១.១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តាមខែពីឆ្នាំ២០១៥ដល់ឆ្នាំ២០១៧

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា P | សីហា P | កញ្ញា P | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៧ | ខែដូចគ្នាឆ្នាំ | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៨% | ៣,០% | ៣,០% | | | | |
| ២០១៦ | ខែដូចគ្នាឆ្នាំ | ៣,០% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣,០% |
| ២០១៥ | ខែដូចគ្នាឆ្នាំ | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |

P:តួលេខខែ កក្កដា សីហា កញ្ញា និងប្រចាំឆ្នាំ២០១៧ ជាតួលេខព្យាករណ៍(តាមវិធីសាស្ត្រ Decomposition)

តារាង១.២. សន្ទស្សន៍ថ្លៃអតិផរណា និងអត្រារួមចំណែកក្នុងអតិផរណា (តាមក្រុមទំនិញ)

| ក្រុមទំនិញ | សន្ទស្សន៍មធ្យមឆមាសទី១ឆ្នាំ២០១៧ | អតិផរណា ឆមាសទី១ឆ្នាំ២០១៦ |
|---|---|---|
| ទំនិញប្រើប្រាស់ (២៥៩ មុខ) | ១៦៨,៩% | ១៦៣,៣% |
| ម្ហូបអាហារ | ២០៨% | ១៩៩,០% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ១៥៩,៧% | ១៥៥,៤% |
| សម្លៀកបំពាក់ និងស្បែកជើង | ១៤៣,៩% | ១៣៩,៦% |
| ផ្ទះសំបែងទឹកអគ្គិសនីឧស្ម័ននិងឥន្ទនៈផ្សេងទៀត | ១២៣,៩% | ១២៤,០% |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ១៥០,២% | ១៤៧,១% |
| សុខាភិបាល | ១៣២,៧% | ១៣០,៦% |
| ការដឹកជញ្ជូន<br>ក្នុងនោះ ប្រេងសាំង | ១១២,៥%<br>៩០,០% | ១០៨,០%<br>៨២,០% |
| ទូរគមនាគមន៍ | ៦៨,៣% | ៦៨,៦% |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

| | | |
|---|---|---|
| ការកម្សាន្ត និងវប្បធម៌ | ១១៩,២% | ១១៦,៨% |
| ការសិក្សា | ១៦០,១% | ១៦០,១% |
| ភោជនីយដ្ឋាន | ២៥០,៥% | ២៣៨,៧% |
| ទំនិញ និងសេវាកម្មផ្សេងៗ | ១៣៩,៦% | ១៣៨,១% |

កំណត់សម្គាល់ : គ្រាគោលគឺត្រីមាសទី៤ ឆ្នាំ២០០៦ = ១០០%

➢ មុខទំនិញដែលឡើងថ្លៃខ្ពស់មានប្រេងសាំង ៩,៥% ត្រីស្រស់ ៨,៤% បន្លែ ៨,២% និងប្រេងម៉ាស៊ូត ៧,៧% ។

➡**អត្រាប្តូរប្រាក់** :ជារួមអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយវត្ថុបរទេសមានស្ថេរភាព។ ប្រាក់រៀលមានការធ្លាក់ថ្លៃធៀបនឹងដុល្លារ និងបាត។

| ប្រភេទ | ចុងឆមាសទី១/២០១៧ | ចុងឆមាសទី១/២០១៦ | បម្រែបម្រួល |
|---|---|---|---|
| **៛/១ដុល្លារ** | ៤០៨៦៛ | ៤០៨៤៛ | ០,០៥% |
| **៛/១បាត** | ១២០៛ | ១១៦៛ | ៣,៤% |
| **៛/១ដុង** | ០,១៨០៛ | ០,១៨៣៛ | -១,៦% |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិក្នុងឆមាសទី១ ឆ្នាំ២០១៧ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

➢ចំណូលអនុវត្តបានចំនួន ៨៦០២ប៊ីលានរៀល គិតជាដុល្លារអាមេរិក មានចំនួន២១៥០,៥លានដុល្លារ ស្មើនឹង ៥៤% នៃផែនការហិរញ្ញវត្ថុប្រចាំឆ្នាំក្នុងនោះ ចំណូលចរន្តមានចំនួន ៨៣០៨ប៊ីលានរៀល គិតជាដុល្លារអាមេរិក មានចំនួន២០៧៧លានដុល្លារ ស្មើនឹង ៧៥% នៃផែនការ និងចំណូលមូលធនចំនួន ២៩៤ប៊ីលានរៀល។

➢បើធៀបនឹងឆមាសទី១ដូចគ្នាចំណូលថវិកាជាតិ កើនឡើង១៧% ដែលក្នុងនោះ ចំណូលចរន្ត កើនឡើង ១៣% ។

➢ ក្នុងចំណូលចរន្ត :ចំណូលសារពើពន្ធក្នុង៦ខែដើមឆ្នាំនេះអនុវត្តបានចំនួន ៧៤៦៨ប៊ីលានរៀល គិតជាដុល្លារអាមេរិក មានចំនួន១៨៦៧លានដុល្លារ ស្មើនឹង ៥៧% នៃផែនការប្រចាំឆ្នាំ។ បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ ២០១៦ចំណូលសារពើពន្ធកើនឡើង ១៣% ដែលក្នុងនោះ៖ ពន្ធនិងអាករគយថយចុះ ២%(តាមអគ្គនាយកដ្ឋានគយ និងរដ្ឋាករ កើនឡើង២%) និងចំណូលពន្ធដារ កើនឡើង ៣០%(តាមអគ្គនាយកដ្ឋានពន្ធដារ កើនឡើង៣១%) ។

ក្រាហ្វ ២.១. សមាសធាតុចំណូលសារពើពន្ធ តាមឆមាស (២០១៤-២០១៦)



**តារាង២.១. សមាសភាពនៃចំណូលចរន្ត**

| មុខចំណូល | អនុវត្ត ផែនការ | %Δធៀបនឹង ឆ.១ឆ្នាំ ២០១៦ |
|---|---|---|
| **ចំណូលសារពើពន្ធ(រតនាគា)** | ៥៧% | +១៣% |
| ✓ពន្ធនិងអាករគយ(**អ.នាគយ និងរដ្ឋាករ**) | ៥១% | +២% |
| -ពន្ធគយ (របបនាំចូល) | ៤៤% | –១២% |
| -អាករពិសេសលើរបបនាំចូល | ៦២% | +១៥% |
| -អាករលើតម្លៃបន្ថែមរបបនាំចូល | ៤៨% | +១% |
| -អាករនាំចេញ | ៣៧% | +១% |
| -អាករបន្ថែមលើផលិផលគេលសិលា | ៥១% | +២៧% |
| ✓ ចំណូលពន្ធដារ(**អ.នា ពន្ធដារ**) | ៦៣% | +៣១% |
| -ពន្ធលើប្រាក់បៀវត្ស | ៤៨% | +៥% |
| - ពន្ធលើប្រាក់ចំណេញ | ៨២% | +៣៣% |
| - ពន្ធលើឈ្នួលផ្ទះ–ដី | ៥៤% | +៣២% |
| - អាករលើផលរបរ | % | –៩៨% |
| - អាករលើតម្លៃបន្ថែម | ៦៥% | +៤៧% |
| -អាករពិសេស | ៥៤% | +១១% |
| -ចំណូលផ្សេងៗ | ៤៨% | +៣៥% |
| -ថវិកាខេត្ត–រាជធានី | ៣៧% | +៣៦% |

| **មុខចំណូល** | អនុវត្ត ផែនការ | %Δធៀបនឹង ឆ.១ឆ្នាំ ២០១៦ |
|---|---|---|
| **ចំណូលមិនមែនសារពើពន្ធ** | ៣៧% | +១៥% |
| ✓កាស៊ីណូ | ៤៣% | +១៥% |
| ✓អាជ្ញាបណ្ណក្នុងស្រុក | ៣៩% | +២១% |
| ✓កម្រៃគ្រប់គ្រង និងទិដ្ឋាកានាំចេញ | ៣០% | +៩១% |
| ✓នេសាទ | ៣៥% | +២២% |
| ✓ រុក្ខាប្រមាញ់ | ៧៤% | +៧៤,៧% |
| ✓សម្បទានរ៉ែ | ១៧% | +១៩,៨% |
| ✓អាកាសចរណ៍ស៊ីវិល | ៥៣% | +៨,៥% |
| ✓ ផលទុនទេសចរណ៍ | ៥១% | +១០១,៥% |
| ✓ប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០% | –១៣,៥% |
| ✓អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ) | ៤៦% | +១៥% |
| ✓ត្រួតពិនិត្យគុណភាពផលិតផល | ៤% | –៨៦% |
| ✓ ជួលសហគ្រាស សម្ភារៈ | ៣៩% | +១៦% |
| ✓លក់អចលនកម្ម (ទ្រព្យសម្បត្តិរដ្ឋ) | % | % |
| ✓ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ | % | +១០% |

➢ចំណាយថវិកាជាតិក្នុងឆមាសទី១ឆ្នាំ២០១៧ អនុវត្តបានចំនួន ៥៦៨៥,៨ប៊ីលានរៀល គិតជាដុល្លារអាមេរិក មានចំនួន១៤២១,២ លានដុល្លារ ស្មើនឹង ៣៦% នៃផែនការប្រចាំឆ្នាំ ក្នុងនោះៈ ចំណាយចរន្តសម្រេចបានចំនួន ៥០១៩ប៊ីលានរៀល ស្មើនឹង ៣៨% នៃផែនការ និងចំណាយមូលធនមានចំនួន ៦៦៦,៨ប៊ីលានរៀល។

➢បើប្រៀបធៀបឆមាសទី១ដូចគ្នាឆ្នាំ២០១៦ ចំណាយថវិកាជាតិ កើនឡើង២០% ក្នុងនោះៈ ចំណាយចរន្ត កើនឡើង២៤% ប៉ុន្តែចំណាយមូលធន ថយចុះ ៣,៦% ។

➢ថវិកាជាតិនាឆមាសទី១ឆ្នាំ២០១៧ មានអតិរេកចំនួន ២៩១៦ប៊ីលានរៀល ស្មើនឹង ៧២៩,១១លានដុល្លារ ស.រ.អា។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុនាចុងឆមាសទី១ឆ្នាំ២០១៧មានលក្ខណៈដូចខាងក្រោមៈ

➢រូបិយវត្ថុ M2 មានចំនួន៦៥២៧១ប៊ីលានរៀល កើនឡើង ២០% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៦។

➢ការកើនឡើងនៃ M2 នេះបណ្តាលមកពីកំណើន នៃរូបិយវត្ថុក្រៅធនាគារ ១៨% ប្រាក់បញ្ញើចរន្ត ២៦%ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ ២៤% និងប្រាក់បញ្ញើជារូបិយបណ្ណ ២០%។

➢ចំនួនប្រាក់រៀលនៅក្នុងនិងក្រៅធនាគារសរុប មានចំនួន ១៦% នៃរូបិយវត្ថុ M2 រីឯប្រាក់បញ្ញើជា រូបិយបណ្ណមានចំនួន ៨៤%។

ក្រាហ្វ៣.សមាសធាតុរូបិយវត្ថុនាចុងឆមាសទី១ឆ្នាំ២០១៧




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន ៧៧៧៣លានដុល្លារកើនឡើង៣៦% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៦

➢**ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជា** ជាទូទៅមានការកើនឡើង ដោយក្នុងឆមាសទី១ ឆ្នាំ២០១៧ មានចំនួន ២៣៨៣៦ប៊ីលានរៀល កើនឡើង ៣៨% បើធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០១៦។

➢**ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ** មានចំនួន ៦២៧៦៩ប៊ីលានរៀល កើនឡើង ១៥% ធៀបនឹង ឆមាសទី១ ឆ្នាំ២០១៦។

➢**ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** មានចំនួន ១៤៦៦៣ប៊ីលានរៀល កើនឡើង ៣០% ធៀប នឹងឆមាសទី១ ឆ្នាំ២០១៦។

➢***អត្រាការប្រាក់ប្រចាំឆ្នាំ:***

| ប្រភេទអត្រាការប្រាក់ | ចុងឆមាសទី១ ឆ្នាំ២០១៧ | ចុងឆមាសទី១ ឆ្នាំ២០១៦ | បម្រែបម្រួល |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,០៣% | ៦,៧៩% | -១១% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៤,៤៨% | ១៧,៣៤% | -១៦% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤១% | ៤,៥២% | -២% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៨០% | ១១,៧៤% | ១% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ១៨% | ២៨,៨% | -៣៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថាកសិករ | ១៨% | ៣១% | -៤២% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | ១៨% | ២២,៨% | -២១% |

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍

ក្នុងឆមាសទី១ ឆ្នាំ២០១៧ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម :

➡កសិកម្ម:

➢តារាងខាងក្រោមបង្ហាញផ្ទៃដីដំណាំផ្សេងៗ ឆ្នាំ ២០១៥ ២០១៦ និង៦ខែដើមឆ្នាំ២០១៧។

| *ប្រភេទដំណាំ* | *ឆមាសទី១-២០១៧* | ឆ្នាំ២០១៦ | ឆ្នាំ២០១៥ |
|---|---|---|---|
| ផ្ទៃដីដាំស្រូវវស្សា (ពាន់ហិកតា) | ១២៦០ | ២៦០០ | ២៥៦២ |
| ផ្ទៃដីដាំពោត (ពាន់ហិកតា) | ១០២,៤ | ១៣៨,២ | ១១១,៦ |
| ផ្ទៃដីដាំដំឡូងឈើ (ពាន់ហិកតា) | ៤៨២ | ៦៧៤,៣ | ៥៧៣,៦ |
| ផ្ទៃដីដាំដំឡូងជ្វា (ពាន់ហិកតា) | ២ | ៥ | ៥,៨ |

| | | | |
|---|---|---|---|
| ផ្ទៃដីដាំបន្លែគ្រប់មុខ (ពាន់ហិកតា) | ២៤,១ | ៤៣ | ៤៧,៤ |
| ផ្ទៃដីដាំសណ្តែកបាយ (ពាន់ហិកតា) | ២៧,៧ | ៤៥,១ | ៥៧,២ |
| ផ្ទៃដីដាំសណ្តែកដី (ពាន់ហិកតា) | ៩,១ | ១៣,២ | ១៥,៥ |
| ផ្ទៃដីដាំសណ្តែកសៀង (ពាន់ហិកតា) | ៤,៨ | ៤០,៦ | ៦៦,៨ |
| ផ្ទៃដីដាំកៅស៊ូសរុប (ពាន់ហិកតា)<br>ក្នុងនោះ ផ្ទៃដីចៀរជ័រ | ៤៣១,៨<br>១៦១,៩ | ៤៣២,៧<br>១២៧ | ៣៨៩<br>១១១,២ |

➢ ផលិតផលនេសាទមានចំនួន ៣០១,៧ **ពាន់តោន** កើនឡើង ៥% បើធៀបនឹងឆមាសទី១ដូចគ្នា ឆ្នាំ២០១៦។

➡ឧស្សាហកម្ម:

➢ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៣៧២០ GWh កើនឡើង១១% ធៀបនឹងឆមាសទី១ឆ្នាំ២០១៦។ ក្នុងនោះ វារីអគ្គិសនីមានចំនួន ១០៤៨ GWh កើនឡើង ១១២% អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន១៨៧២,៨GWHកើនឡើង១៩% អគ្គិសនីផ្គត់ផ្គង់ដោយប្រេងខ្មៅ ១៥៧,៣ GWh ថយចុះ ៥៤% និងអគ្គិសនីនាំចូលពីប្រទេសជិតខាងដោយEDCមានចំនួន ៦៤០,៩ ថយចុះ ៣២%។

➢ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៣៣៣៦លានដុល្លារ កើនឡើង ៤% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៦។

➢ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាសនៅក្រសួងឧស្សាហកម្ម:

| ប្រភេទ | ចំនួន :ឆមាសទី១ ឆ្នាំ២០១៧ | ចំនួន:ឆមាសទី១ ឆ្នាំ២០១៦ | បម្រែបម្រួល |
|---|---|---|---|
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ៤៦ | ៧៧ | -៤០% |
| ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៦២១ | ១៥២០ | +៧% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម(បើកថ្មី) | ១១២ | ១៦៧ | -៣៣% |
| ឧស្សាហកម្មធនតូច និងសិប្បកម្ម (បន្ត) | ១៥២ | ១៦០ | -៥% |

➡**សំណង់**:

➢សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន៧២៨៤,៧ពាន់ម$^2$ថយចុះ១០%បើធៀបនឹងឆមាសទី១ ឆ្នាំ២០១៦។ ការអនុញ្ញាតនេះ ជាទឹកប្រាក់មានចំនួន ៤៩៤៣,៥លានដុល្លារ កើនឡើង២៨%បើធៀបនឹង៦ខែដើមឆ្នាំ២០១៦។ក្នុងនោះប្រភេទសំណង់សំខាន់ៗមាន :

| *ប្រភេទសំណង់* | ពាន់ម$^2$ :ឆមាសទី១ ឆ្នាំ២០១៧ | ពាន់ម$^2$ :ឆមាសទី១ ឆ្នាំ ២០១៦ | បម្រែបម្រួល |
|---|---|---|---|
| លំនៅឋាន | ៣៩៤៩,៤ | ៣៦៧៥ | +៧% |
| ឧស្សាហកម្ម | ៣៨៤,៧ | ១២៨០ | -៧០% |
| ពាណិជ្ជកម្ម | ២៥៧៨,៣ | ៥៣១៨,៣ | -៥២% |
| ទេសចរណ៍ | ៣៥៥,៨ | ២០០,៤ | +៧៨% |
| ... | | | |
| អនុញ្ញាតសរុប | ៧២៨៤,៧ | ៨០៥០,១ | -១០% |

➢ **ដូច្នេះ** ក្នុងការអនុញ្ញាតឆមាសទី១ ឆ្នាំនេះ សំណង់ដែលពេញនិយមគឺលំនៅដ្ឋាន (៥៤,២១% នៃផ្ទៃក្រឡាសរុប) និងពាណិជ្ជកម្ម (៣៥,៣៩% នៃផ្ទៃក្រឡាសរុប)។

➡**ការងារ:**

| ប្រភេទ | ឆមាសទី១ ឆ្នាំ ២០១៧ (នាក់) | ឆមាសទី១ ឆ្នាំ ២០១៦ (នាក់) | បម្រែបម្រួល |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារធ្វើ(ទីភ្នាក់ងារមុខរបរនិងការងារ) | ៧៧៤៣ | ៥៥៧៩ | +៣៩% |
| អ្នកទទួលបានការធ្វើតាមរយៈក្រសួងនិងក្រុមហ៊ុន | ៨៧៨៦៨ | ៦១៧០២ | +៤២% |
| អ្នកទទួលបានការធ្វើក្នុងប្រទេស | ៦៩៩១៦ | ៤៦២៨៦ | +៥១% |
| អ្នកទទួលបានការធ្វើក្រៅប្រទេស | ១៧៩៥២ | ១៥៤១៦ | +១៦% |

➡**វិនិយោគ:**

➢គម្រោងវិនិយោគ**អនុញ្ញាតដោយ** ក.អ.ក. (ថ្មី និងពង្រីក)

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ២០១៧ | ឆមាសទី១ ឆ្នាំ២០១៦ | បម្រែបម្រួល |
|---|---|---|---|
| **អនុញ្ញាតសរុប** (លានដុល្លារ) ក្នុងនោះ : | ៣០៣៦,៨ | ១៨៧៩,៨ | +៦២% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១៩០,៦ | ៧៤,៦ | +១៥៦% |
| វិស័យឧស្សាហកម្ម | ៦៩៨,៩ | ៧៧០,៥ | -៩% |
| ក្នុងនោះ តំបន់សេដ្ឋកិច្ចពិសេស | ៣៣៧,៥ | ៥៨,៤ | +៤៧៧% |
| វិស័យទេសចរណ៍ | ៦៤៧,៨ | ៦៦៤,៧ | -៣% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១៤៩៩,៥ | ៣៧០,០ | +៣០៥% |
| **គម្រោងថ្មី និងគម្រោងពង្រីក (ចំនួន)** | ៨៧,០ | ៧៩,០ | +១០% |
| **បង្កើតការងារ (ពាន់នាក់)** | ១១៩,១ | ៧៦,៤ | +៥៦% |

➡**សេវាកម្ម និងទេសចរណ៍:**

➢ការចុះបញ្ជី និងលុបចេញពីបញ្ជី :

| *ប្រភេទ* | *ចំនួន* :ឆមាស១ ឆ្នាំ ២០១៧ | *ចំនួន* :ឆមាស១ ឆ្នាំ ២០១៦ | បម្រែបម្រួល |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៦៦៨ | ២០៥៩ | +៣០% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២០ | ២ | +៩០០% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | ៣៤៥១ | |

➢**ទំនិញឆ្លងកាត់តាមកំពង់ផែ** (សរុប៥កំពង់ផែ)មានចំនួន៥១១០ពាន់តោន កើនឡើង១០%ធៀបនឹងឆមាសទី១ ឆ្នាំ២០១៦។ ក្នុងនោះ :

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ២០១៧ (ពាន់តោន) | ឆមាសទី១ឆ្នាំ២០១៦(ពាន់តោន) | បម្រែបម្រួល |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ១៣២២,៧ | ១២០៩ | +៩% |
| កំពង់ផែកំពង់សោម | ៣៣៧៨,៦ | ២៩០៨,៧ | +១៦% |
| កំពង់ផែស្រែអំបិល និងកោះកុង | ៦៤,៨ | ២២៧,៩ | –៧២% |
| កំពង់ផែឧកញ៉ាម៉ុង | ៣៤៣,៨ | ២៩១,៥ | +១៨% |

↳**អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍**

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ២០១៧(ពាន់នាក់) | ឆមាសទី១ ឆ្នាំ២០១៦(ពាន់នាក់) | *បម្រែបម្រួល* |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១១៥,៩ | ៨៨,១ | +៣២% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២៦៦,៩ | ២១១,៦ | +២៦% |

| | | | |
|---|---|---|---|
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៣៦៧៦,១ | ២៩៩៦,៩ | +២៣% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ៨៤២ | ៦៦៩,៧ | +២០% |
| អ្នកទេសចរអន្តរជាតិមកដល់កម្ពុជា | ២៦៦២,៤ | ២៣០២,០ | +១៣% |
| ✓តាមផ្លូវអាកាស | ១៦០៥,៧ | ១២៣០,៩ | +២៣% |
| ✓ តាមផ្លូវគោក និងទឹក | ១០៥៦,៧ | ១០៧១,១ | +០% |

➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០១៧ | ឆមាសទី១ ឆ្នាំ២០១៦ | បម្រែបម្រួល |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១០១,៩ | ៨៦,០ | ១៩% |
| ក្នុងនោះទទួល | ១៣,៨ | ១២,៨ | ៧% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៦៤៦,២ | ៦២៨,៨ | ៣% |
| ក្នុងនោះទទួល | ៣២៦,៨ | ២៩០,៥ | ១៣% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១៤ ៦០៦ | ១៦ ៩៨៧,៣ | -១៤% |
| ក្នុងនោះហៅចូល | ៤២៦២,៣ | ៤ ៩៣០,៤ | -១៤% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៥៧ ៩០៥,៥ | ៦៦ ៣៥០,៨ | -១៣% |
| ក្នុងនោះហៅចូល | ៥៧ ៤៩៥,២ | ៦៦ ០៣១,០ | -១៣% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

ពីប្រភពអគ្គនាយកដ្ឋានគយ និងរដ្ឋាករ:

➡ការនាំចូលក្នុងឆមាសទី១ ឆ្នាំ២០១៧មានចំនួន២៧៤៣៩ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៦៨៥៩,៧ លានដុល្លារ កើនឡើង ៦% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៦។ក្នុងនោះមុខទំនិញគួរកត់សម្គាល់មាន:

| បរិយាយ | %∆ធៀបនឹងឆ.ទី១ ឆ្នាំ២០១៦ | បរិយាយ | %∆ធៀបនឹងឆ.ទី១ ឆ្នាំ ២០១៦ |
|---|---|---|---|
| ប្រេងសាំង | +៨% | ត្រាក់ទ័រនិងគោយន្ត(ជាគ្រឿង) | -៩% |
| ប្រេងម៉ាស៊ូត | ០% | ម៉ូតូ(ជាគ្រឿង) | -១៥% |
| ឧស្ម័ន | +១៥% | អង្ករ | -៨៤% |
| ប្រេងខ្មៅ | -៤១% | ផ្លែឈើនិងបន្លែ | +២៧% |
| អគ្គិសនីនាំចូល | -៣២% | ជីនិងថ្នាំកសិកម្ម | +៥៦% |
| ដែកសំណង់ | +៨% | បារី | -១០% |
| ស៊ីម៉ង់ត៍ | -៦% | ភេសជ្ជៈ | +១៥% |
| គ្រឿងអេឡិចត្រូនិក | +៣% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៣% |
| រថយន្តសរុប (ជា ព.ល.រ) | +៨% | | |
| រថយន្តសរុប (ជាគ្រឿង) | -១៤% | | |

➡**ការនាំចេញ** ក្នុងឆមាសទី១ ឆ្នាំ២០១៧ មានចំនួន ២១៤៦៨ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៥៣៦៧ លានដុល្លារ (មានចំនួន៧៨,៣%នៃការនាំចូល) មានការ កើនឡើង ១២%ធៀបនឹងឆមាសទី១ ឆ្នាំ២០១៦។ ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន៖

| ទំនិញ | %∆ធៀបនឹងឆ.ទី១ ឆ្នាំ២០១៦ | ទំនិញ | %∆ធៀបនឹងឆ.ទី១ ឆ្នាំ២០១៦ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | -១៤% | ផលិតផលនេសាទ | +៨២% |
| វាយនភណ្ឌនិងស្បែកជើង | +៦% | កៅស៊ូ | +៣០% |
| អង្ករ | +២% | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងឆមាសទី១ ឆ្នាំ២០១៧សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម:

| ល.រ. | សូចនាករ | % ∆ ធៀបនឹងឆមាស១ ឆ្នាំ២០១៦ | កំណត់សម្គាល់ |
|---|---|---|---|
| ១ | សន្ទស្សន៍ថ្លៃត្រីស្រស់ | +៨,៤% | — |
| ២ | សន្ទស្សន៍ថ្លៃបន្លែ | +៨,២% | — |
| ៣ | ចំនួនរោងចក្រថ្មីដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម | -៤០% | — |
| ៤ | ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | -៣៣% | |
| ៥ | សំណង់អនុញ្ញាតឲ្យសាងសង់ ក្នុងឧស្សាហកម្ម | -៧០% | — |
| ៦ | សំណង់អនុញ្ញាតឲ្យសាងសង់ ក្នុងពាណិជ្ជកម្ម | -៥២% | |

## ៧) សេចក្តីសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម:***

១)ការអនុលោមតាមកិច្ចព្រមព្រៀងពន្ធគយនៃសមាគមសេដ្ឋកិច្ចអាស៊ាន និងឧស្សាហូបនីយកម្មក្នុងស្រុកជំនួសការនាំចូល ដូចជា ស៊ីម៉ង់ ភេសជ្ជៈ ជាដើម ធ្វើឲ្យចំណូលពន្ធគយកម្ពុជាថយចុះប្រហែល ៩៨,៥ លានដុល្លារក្នុងមួយឆ្នាំ។ ក្នុង៦ខែដើមឆ្នាំ២០១៧ នេះ ចំណូលពន្ធគយមានចំនួនប្រហែល ៤៧% នៃចំណូលសារពើពន្ធ ខណៈដែលចំណូលនេះមានចំនួន ៥៤% ក្នុងឆមាសទី១ ឆ្នាំ២០១៦។ ដើម្បីប៉ះប៉ូវការបាត់បង់នេះ ពន្ធលើតម្លៃបន្ថែម និងអាករពិសេសលើទំនិញនាំចូលមួយចំនួននឹងត្រូវពង្រឹង និងកែសម្រួល ដើម្បីរក្សានិរន្តរភាពចំណូលថវិកាក្នុងរយៈពេលមធ្យមខាងមុខ។

២)ការអនុញ្ញាតិឲ្យសាងសង់ក្នុងឆមាសទី១ ឆ្នាំ២០១៧ មានចំនួនជាទឹកប្រាក់ ៤ ៩៤៤ លានដុល្លារ កើនឡើង ២៨% ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៦។ នេះជាតួលេខមួយគួរឲ្យចាប់អារម្មណ៍ដែលសំណង់ត្រូវបានចាត់ទុកថា ជាវិស័យរីកដុះដាលខ្លាំងក្លាបំផុត ជាមួយនឹងចំនួនក្រុមហ៊ុនសំណង់ជាង ៨០០ ក្រុមហ៊ុន ក្នុងស្រុក និងពីបរទេសជាង២០ប្រទេស។

ទោះបីសំណង់កំពុងមានសន្ទុះក៏ដោយ ក៏វិស័យនេះកំពុងប្រឈមបញ្ហាគួរឲ្យបារម្ភមួយចំនួន ដូចជាគុណភាពសំណង់ ស្តង់ដារបច្ចេកទេស ការគ្រប់គ្រងនៅមានចន្លោះប្រហោង កង្វះកម្មករជំនាញ។ល។ ក្នុងចំណោមបញ្ហាទាំងឡាយ គួរកត់សម្គាល់មួយចំនួន ដូចជា៖ គម្រោងមួយចំនួនអូសបន្លាយយូរអង្វែង (ឧ. ប៊ូយ៉ុង) ប្រព័ន្ធក្រោមដីមិនមានសង្គតិភាពជាមួយសំណង់លើដី ទំហំផ្លូវថ្នល់ និងការទុកចំណីផ្លូវតូចពេកជាដើម។

ការខ្វះបទបញ្ញត្តិ និងការអនុវត្តបទបញ្ញត្តិនៅមានកម្រិត ជាមូលហេតុចម្បងនៃបញ្ហាក្នុងវិស័យសំណង់។ ក្រសួងនិងអាជ្ញាធរពាក់ព័ន្ធ ត្រូវមានវិធានការណ៍សមស្របទាន់ពេលវេលាលើការត្រួតពិនិត្យគុណភាព បច្ចេកទេសសាងសង់ ការគ្រប់គ្រងទាក់ទងនឹងការពុះដីលក់ និងការទុកចំណីផ្លូវជាដើម។ គួរដាក់ស្លាកសញ្ញាអំពីចម្ងាយពីផ្លូវថ្នល់ដែលត្រូវរក្សាទុកជាចំណីផ្លូវឲ្យបានច្រើន នៅតាមទីកន្លែងណាដែលសំណង់បម្រុងនឹងកើតមាន៕

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៣/០៧/១៧<br>ម៉ោង០៩:៣០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ឆយ អូន** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៤/០៧/១៧<br>ម៉ោង១១:០០នាទី | ជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ហោ ណាំបូរ៉ា** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១០/០៧/១៧<br>ម៉ោង១០:០០នាទី | តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អានសារលិខិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជូនជនរួមជាតិក្នុងឱកាសពិធីអបអរសាទរ " តំបន់ប្រាសាទសំបូរព្រៃគុក " ត្រូវបានគណៈកម្មការបេតិកភណ្ឌពិភពលោក(យូណេស្កូ) ចុះទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ នៅទីក្រុង Krakow ប្រទេសប៉ូឡូញ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៤/០៧/១៧<br>ម៉ោង១៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរបុណ្យឯករាជ្យជាតិបារាំង រៀបចំដោយស្ថានទូតបារាំងប្រចាំនៅកម្ពុជា នៅស្ថានទូតបារាំង។ |
| ៥ | ១៧/០៧/១៧<br>ម៉ោង១៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរការបញ្ចូល " តំបន់ប្រាសាទសំបូរព្រៃគុក " ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅពហុកីឡាដ្ឋានជាតិអូឡាំពិក។ |
| ៦ | ២៣/០៧/១៧<br>ម៉ោង០៩:០០នាទី | ចូលរួមកិច្ចប្រជុំពិសេស ដើម្បីដកពិសោធន៍អំពីចំណុចខ្លាំង និងចំណុចខ្វះខាតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤កន្លងមក និងវិធានការគន្លឹះសំខាន់ៗ ដើម្បីទទួលបានជោគជ័យក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ២៤/០៧/១៧<br>ម៉ោង០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវឯកសារ "ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៨ | ២៧/០៧/១៧<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែមិថុនា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | **២៩/០៧/១៧ ម៉ោង០៨:០០នាទី** | បន្តចូលរួមកិច្ចប្រជុំពិសេស ដើម្បីដកពិសោធន៍អំពីចំណុចខ្លាំង និងចំណុចខ្វះខាតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤កន្លងមក និងវិធានការគន្លឹះសំខាន់ៗ ដើម្បីទទួលបានជោគជ័យក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិ ចុះជួយខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | **៣០/០៧/១៧ ព្រឹកនិងល្ងាច** | ចូលរួមប្រជុំគណៈកម្មាធិការកណ្តាលបើកទូលាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលមហោស្រពកោះពេជ្រ។ |

# ព្រឹត្តិបត្រព័ត៌មាន




## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in